ទីស្ដីការក្រសួងយុត្តិធម៌
លេខ ១៤៤ រប-៩៦

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ជម្រាបមក**

**លោកព្រះរាជអាជ្ញា អមតុលាការខេត្ត ក្រុង**

**សូមជ្រាប។**

**កម្មវត្ថុ:** អំពីរបាយការណ៍ត្រួតពិនិត្យមន្ទីឃុំឃាំង និងពន្ធនាគារខេត្ត ក្រុង ។

**យោង:** សារាចរលេខ ១០៩២ ព.គខក្រ-៩៥ ចុះថ្ងៃទី២៥-១០-៩៥ និងលិខិតលេខ១០៤០ចុះ ព.គខក្រ-៩៥ ចុះថ្ងៃទី១៧-១១-៩៥ របស់ក្រសួងយុត្តិធម៌ ។

ខ្ញុំសូមជម្រាបលោកថា កន្លងមកក្រសួងបានធ្វើគំរូរបាយការណ៍ ស្ដីពីការត្រួតពិនិត្យមន្ទីរឃុំឃាំងនិងពន្ធនាគារផ្ញើជូនអយ្យការ អមតុលាការខេត្ត-ក្រុង រួចហើយប៉ុន្តែនៅមានខ្វះខាតចំណុចមួយចំនួនលើគំរូរបាយការណ៍ ដែលក្រសួងបានធ្វើផ្ញើរួចហើយនោះ ។

ដូច្នេះ ចាប់ពីពេលនេះតទៅសូមលោកព្រះរាជអាជ្ញាចាត់ការធ្វើរបាយការណ៍ និងតារាងពិរុទ្ធជនផ្ញើទៅក្រសួងយុត្តិធម៌អោយបានទៀងទាត់រៀងរាល់ខែ និងបំណាច់ឆ្នាំអោយបានម្មត់ចត់ និងត្រឹមត្រូវទៅតាមគំរូរបាយការណ៍ត្រួតពិនិត្យមន្ទីរឃុំឃាំង និងពន្ធនាគារថ្មីនេះវិញ។ ក្នុងគំរូរបាយការណ៍ថ្មីនេះចាំបាច់ត្រូវតែបំពេញអោយបានគ្រប់ចំណុចទោះមានក្ដី ឬមិនមានក្ដី ប៉ុន្តែបើមានចំណុចណាត្រូវរាយការណ៍បន្ថែម ព្រះរាជអាជ្ញាអាចរាយការណ៍លើសពីចំណុចក្នុងគំរូរបាយការណ៍នេះបន្ថែមទៀតបាន ។

ធ្វើនៅភ្នំពេញ ថ្ងៃទី០៧ ខែកម្ភៈ ឆ្នាំ១៩៩៦

**រដ្ឋមន្ត្រី**

**ចែម ស្នួន**